ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លេខាធិការដ្ឋាន គ.ជ.អ.ប
ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង
លេខ: ០១ សកណ

# សេចក្តីកំណត់

## ស្តីពី

## របៀបរបបធ្វើការងាររបស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សម្រាប់ជួយគាំទ្រដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

- យោងព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២៣អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងសេចក្តីសំរេចលេខ១២ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ
- យោងសេចក្តីសំរេចលេខ ០៣៧ សសរ/គ.ជ.វ.វ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបង្កើតក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង សម្រាប់ជួយគាំទ្រដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- បានទទួលការឯកភាព នាកិច្ចប្រជុំលើកទី១ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង

# ជំពូកទី១
# អំពីកិច្ចប្រជុំ

**ប្រការ ១ .–**

ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង ហៅកាត់ថា **ក.ព.ប.អ** ដែលត្រូវបានបង្កើតឡើងសម្រាប់ជួយជំរុញ និងគាំទ្រដល់ការអនុវត្តគម្រោងសាកល្បងការិយាល័យច្រកចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ត្រូវប្រជុំសាមញ្ញដោយទៀងទាត់រៀងរាល់បី (០៣) ខែម្តង និងអាចប្រជុំវិសាមញ្ញបានតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន ឬ សមាជិកបី (០៣)រូប នៃ **ក.ព.ប.អ** ។

**ប្រការ ២ .–**

ក្នុងករណីចាំបាច់ ក.ព.ប.អ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដែលមិនមែនជាសមាជិក ក.ព.ប.អ តំណាងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តំណាងអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀតចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួនបាន ។

**ប្រការ ៣ .–**

លិខិតអញ្ជើញចូលរួមប្រជុំ ត្រូវផ្ញើជូនសមាជិក ក.ព.ប.អ យ៉ាងតិចបី (០៣)ថ្ងៃការងារ មុនថ្ងៃប្រជុំ ។

លិខិតអញ្ជើញប្រជុំទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ និងឯកសារលិខិតស្នាមដែលពាក់ព័ន្ធសម្រាប់កិច្ចប្រជុំ និងសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំលើកមុន ។

**ប្រការ ៤ .–**

កិច្ចប្រជុំរបស់ ក.ព.ប.អ ដែលអាចចាត់ទុកជាផ្លូវការបាន លុះត្រាតែមានសមាជិកចូលរួមប្រជុំមានចំនួនលើសពីពាក់កណ្តាល នៃចំនួនសមាជិកទាំងអស់របស់ ក.ព.ប.អ ។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ក.ព.ប.អ ។ ក្នុងករណីសមាជិក ក.ព.ប.អ មិនអាចចូលរួមប្រជុំបាន សមាជិកនោះ ត្រូវចាត់តាំងតំណាងមួយរូប ដើម្បីចូលរួមកិច្ចប្រជុំ ដោយផ្ទេរសិទ្ធិឱ្យតំណាងរូបនោះមានសិទ្ធិសម្រេចជំនួសខ្លួន។

**ប្រការ ៥ .–**

ក.ព.ប.អ ត្រូវដំណើរការប្រជុំតាមកម្មវិធីដូចខាងក្រោម :

- ការចុះបញ្ជីវត្តមាន
- ពិនិត្យកូរ៉ុមសម្រាប់ការប្រជុំ

- ពិនិត្យ និងអនុម័តរបៀបវារៈនៃកិច្ចប្រជុំ
- ពិភាក្សា និងអនុម័តលើប្រធានបទនីមួយៗ តាមរបៀបវារៈនៃកិច្ចប្រជុំ មានជាអាទិ៍:
  - ក. ពិនិត្យ ពិភាក្សា និងអនុម័តលើប្រធានបទនីមួយៗ តាមរបៀបវារៈជាបន្តបន្ទាប់
  - ខ. បញ្ហាផ្សេងៗ

**ប្រការ ៦ .–**

សេចក្ដីសម្រេចនៃកិច្ចប្រជុំរបស់ ក.ព.ប.អ ដែលអាចចាត់ទុកជាការបាន លុះត្រាតែសេចក្ដីសម្រេចនោះត្រូវបានអនុម័តដោយសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំ ។

ក្នុងករណី ការអនុម័តមានសម្លេងស្មើគ្នា សម្លេងប្រធានអង្គប្រជុំមានឧត្តមានុភាព ។

## ជំពូកទី២
## សិទ្ធិអំណាចរបស់ប្រធានអង្គប្រជុំ

**ប្រការ ៧ .–**

គ្រប់កិច្ចប្រជុំរបស់ ក.ព.ប.អ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់ប្រធាន ក.ព.ប.អ ។ ក្នុងករណីប្រធាន ក.ព.ប.អ អវត្តមាន ប្រធានត្រូវចាត់តាំងសមាជិកមួយរូបជាតំណាង ដើម្បីដឹកនាំការប្រជុំ ។

ប្រធានអង្គប្រជុំ ត្រូវធានាឱ្យដំណើរការនៃកិច្ចប្រជុំ បានប្រព្រឹត្តទៅប្រកបដោយរបៀបរៀបរយ សណ្ដាប់ធ្នាប់ល្អ និងមានលក្ខណៈប្រជាធិបតេយ្យ ។

## ជំពូកទី៣
## កំណត់ហេតុនៃកិច្ចប្រជុំ និងរបាយការណ៍សកម្មភាព

**ប្រការ ៨ .–**

គ្រប់កិច្ចប្រជុំត្រូវមានកំណត់ហេតុនៃអង្គប្រជុំ ។ ប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំដោយភ្ជាប់ជាមួយបញ្ជីវត្តមាន ត្រូវប្រគល់ជូនសមាជិកគ្រប់រូបនៃ ក.ព.ប.អ និងផ្ញើជូនទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និង គ.ជ.អ.ប ។

**ប្រការ ៩ .–**

សមាជិកអចិន្ត្រៃយ៍នៃ ក.ព.ប.អ អាចប្រើប្រាស់មន្ត្រីក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីជួយរៀបចំរបៀបវារៈនៃកិច្ចប្រជុំ ឯកសារពាក់ព័ន្ធនានា និងលិខិតអញ្ជើញប្រជុំ ។

**ប្រការ ១០ .–**

រៀងរាល់បីខែម្តង ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង ជូន គ.ព.ប.អ ។ របាយការណ៍នេះ ត្រូវផ្ញើជូនក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័នពាក់ព័ន្ធ និង គ.ជ.អ.ប ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ ១១ .–**

សេចក្តីកំណត់ស្តីពីរបៀបរបបធ្វើការងាររបស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង នឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩*

**ជ.ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង**

**ប្រធាន**

**សក់ សេដ្ឋា**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ.ជ.អ.ប
- ក្រសួងមហាផ្ទៃ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជធានី និង គ្រប់ខេត្តពាក់ព័ន្ធ
- គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន(DFGG )

( ដើម្បីជូនជ្រាប )

- ឯកសារ-កាលប្បវត្តិ